00225169

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C33/I/7

## អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៩)

អង្គបុរេជំនុំជម្រះ

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន (ប្រធាន)
ចៅក្រម Rowan DOWNING
ចៅក្រម នី ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 09 / 2008
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fay

កាលបរិច្ឆេទ: ២៦ កញ្ញា ២០០៨

សាធារណៈ:

សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**

នួន ជា

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោក ហុង គឹមសួន
លោក ឡោ ជុនធី
លោក នី ចាន់ឌី
លោក គង់ ពិសី
Silke STUDZINSKY
លោក យុង ផានិត
លោក គឹម ម៉េងឃី
Martine JACQUIN

**សហមេធាវីការពារក្តី**

លោក សុន អរុណ
Michiel PESTMAN
Victor KOPPE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 09 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fay

C33/I/7

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៩)

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" ទទួលបាន"បណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាស្តីពីលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន" ("បណ្តឹងឧទ្ធរណ៍") ដែលសហមេធាវីការពារក្តីលោក **នួន ជា** ("ជនត្រូវចោទ") បានដាក់នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៨ ។

## ជំពូក ១ - សេចក្តីផ្តើម

១. នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត បានចេញដីកាមួយ "ស្តីពីលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន" ("ដីកា") ដែលសហចៅក្រមស៊ើបអង្កេត "បានបញ្ជាក់ថា ជនជាប់ឃុំនៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក គ្មានសិទ្ធិធ្វើការប្រាស្រ័យទាក់ទងគ្នាឡើយ។"[១] សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថា "នៅក្នុងការអនុវត្ត ការដាក់ឱ្យនៅដាច់ដោយឡែក តាមលក្ខណៈជាក់ស្តែង មានន័យថា ជាការដាក់ជនជាប់ឃុំទាំងអស់ឱ្យនៅដាច់ដោយឡែកពីគ្នានៅក្នុងមន្ទីរឃុំឃាំង។"[២]

២. សហមេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍ចំពោះដីកានេះ ដែលបានចុះនៅ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨។

៣. នៅពេលទទួលបានសំណើរបស់សហមេធាវីការពារក្តី អង្គបុរេជំនុំជម្រះបានពន្យារពេលថ្ងៃផុតកំណត់នៃការដាក់សារណា រហូតដល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៨។

៤. សហមេធាវីការពារក្តីបានដាក់ "សារណាបណ្តឹងឧទ្ធរណ៍ចំពោះលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្នរបស់ខ្លួន" ("សារណាបណ្តឹងឧទ្ធរណ៍") នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៨។

---

[១] ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ A169/II ("ដីកា") ទំព័រទី ៥។ ដីកានេះត្រូវបានជូនដំណឹងដល់ជនត្រូវចោទនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨។

[២] ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន វាក្យខណ្ឌទី ៦។

៥. សហព្រះរាជអាជ្ញាបានដាក់ "សេចក្តីសន្និដ្ឋានតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះការដាក់ជនជាប់ឃុំឱ្យនៅដាច់ដោយឡែកពីគ្នា នៅក្នុងមន្ទីរឃុំឃាំង" ("សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា") នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៨ ដោយលើកឡើងថា "ខ្លួនមិនជំទាស់ចំពោះបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ដែលស្នើសុំឱ្យបដិសេធចោលដីកាដាក់ជនជាប់ឃុំឱ្យនៅដាច់ដោយឡែកពីគ្នា ដែលដីកានោះបង្គាប់ការដាក់ជនជាប់ឃុំឱ្យនៅដាច់ដោយឡែកពីគ្នា ដើម្បីរារាំងការប្រាស្រ័យទាក់ទងគ្នា។"[៣]

៦. ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សេចក្តីសន្និដ្ឋានតបឡើយ។

៧. នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានសម្រេចថា បណ្តឹងឧទ្ធរណ៍នេះ នឹងយកមកធ្វើការសម្រេច ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគី ហើយអនុញ្ញាតឱ្យសហមេធាវីការពារក្តីលោក នួន ជា ដាក់សារណាតបទៅនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា ក្នុងរយៈពេលប្រាំ(៥)ថ្ងៃ។[៤] សហមេធាវីការពាក្តីមិនបានដាក់សារណាតបណាមួយឡើយ។

៨. អង្គបុរេជំនុំជម្រះបានទទួលសំណើមួយច្បាប់ ដែលស្នើសុំការអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី។ ប៉ុន្តែ អង្គបុរេជំនុំជម្រះបានធ្វើការបដិសេធសំណើនេះចោល ដោយសារតែអង្គបុរេជំនុំជម្រះ បានទទួលព័ត៌មានគ្រប់គ្រាន់ ក្នុងការសម្រេចបណ្តឹងឧទ្ធរណ៍នេះ។[៥]

---

[៣] សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះដីកាឃុំខ្លួននៅដាច់ដោយឡែកពីគ្នា ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៨ C33/I/4 ("សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា") វាក្យខណ្ឌទី ២។

[៤] សេចក្តីសម្រេចចំពោះការបញ្ជាក់លើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ដែលប្តឹងប្រឆាំងចំពោះលក្ខខណ្ឌនៃការឃុំខ្លួន ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៨ C33/I/5។

[៥] សេចក្តីសម្រេចលើសំណើសុំអនុញ្ញតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨ C33/I/6។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00225172

C33/I/7

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៩)

## ជំពូក ២ - ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៩. នៅក្នុង "សេចក្តីសម្រេចលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ដែលលោក អៀង សារី បានដាក់ប្តឹងចំពោះសិទ្ធិចូលសួរសុខទុក្ខ" អង្គបុរេជំនុំជម្រះបានវិនិច្ឆ័យឃើញនាពេលមុនថា បណ្តឹងឧទ្ធរណ៍ដែលជនត្រូវចោទ អៀង សារី ប្តឹងចំពោះសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនេះ អាចទទួលយកបាន ដោយសារតាមអនុភាពរបស់វា សេចក្តីសម្រេចនោះជា ដីកាបង្គាប់ដាក់ជនជាប់ឃុំឱ្យនៅដាច់ដោយឡែកពីគ្នា ("បណ្តឹងឧទ្ធរណ៍របស់លោក នួន ជា") ដោយសារមូលដ្ឋានដូចខាងក្រោម:

> "អង្គបុរេជំនុំជម្រះយល់ថា អំណះអំណាងរបស់សហមេធាវី អាចត្រូវបានគេមើលឃើញថា ជាការតវ៉ាប្រឆាំង នឹងវិធានដ៏តឹងរឹងធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ដែលមិនបានគោរពដល់សេចក្តីថ្លៃថ្នូរពេញលេញរបស់ជនត្រូវចោទ។
>
> ទាក់ទងនឹងសិទ្ធិក្នុងការគោរពដល់សេចក្តីថ្លៃថ្នូរបស់មនុស្សជាតិ និងការលើកយកមកពិចារណានូវកាតព្វកិច្ច ដូចដែលបានបញ្ញត្តិនៅក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះយល់ឃើញថាបណ្តឹងឧទ្ធរណ៍ គឺស្ថិតក្រោមការអនុវត្តន៍នៃវិធាន ៧៤(៣)(ច) នៃវិធានផ្ទៃក្នុង។"[៦]

១០. បណ្តឹងឧទ្ធរណ៍នេះ តាមអានុភាពរបស់វា ត្រូវបានគេប្តឹងចំពោះដីកាបង្គាប់ដាក់ជនជាប់ឃុំឱ្យនៅដាច់ដោយឡែកពីគ្នា ដែលចេញដោយសហចៅក្រមស៊ើបអង្កេត។ សហមេធាវីការពារក្តីអះអាងថា ដីកាបែបនេះប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទ ដែលទទួលបានការប្រព្រឹត្តដល់ខ្លួនដោយមនុស្សធម៌។[៧] ដោយសារមានមូលហេតុលើកឡើងនៅក្នុងសេចក្តីសម្រេចមុន អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះស្ថិតនៅក្នុងវិសាលភាពនៃវិធាន ៧៤(៣)(ច) នៃវិធានផ្ទៃក្នុង។

---

[៦] សេចក្តីសំរេចស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អំពីសិទ្ធិជួបសួរសុខទុក្ខ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨ A104/II/4 វាក្យខណ្ឌទី ៦ វាក្យខណ្ឌទី ៩ និងវាក្យខណ្ឌទី ១០។

[៧] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ២០។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.

១១. ដោយពិចារណាឃើញថា បណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់នៅក្នុងរយៈពេលកំណត់ ដែលត្រូវបានពន្យារពេលដោយអង្គបុរេជំនុំជម្រះ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន។

## ជំពូក ៣ - សេចក្តីវិនិច្ឆ័យ

១២. នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានសម្រេចលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ហើយបានចេញ "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទនឹងប្រពន្ធរបស់គាត់" ("សេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមេសា")។[៨] នៅក្នុងសេចក្តីសម្រេចនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេត អាចដាក់កម្រិតទំនាក់ទំនងរវាងជនជាប់ឃុំនៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ប្រសិនបើជាវិធានការចាំបាច់ និងមានសមាមាត្រទៅនឹងការការពារផលប្រយោជន៍នៃកិច្ចស៊ើបសួរ។[៩] អង្គបុរេជំនុំជម្រះបានបន្ថែមទៀតថា ការកម្រិតទំនាក់ទំនងត្រូវបង្គាប់តាមរយៈការចេញសេចក្តីសម្រេចមួយដែលមានសម្អាងហេតុ ហើយត្រូវបង្ហាញឃើញឱ្យច្បាស់ថា ផលប្រយោជន៍មួយណាដែលត្រូវការពារ ហើយការកម្រិតគួរផ្អែកលើការការពារផលប្រយោជន៍នោះ។[១០]

១៣. នៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមេសា អង្គបុរេជំនុំជម្រះក៏បានរកឃើញថា ដោយសារបទល្មើសដែលបានចោទប្រកាន់ ត្រូវបានប្រព្រឹត្តឡើងកាលពី សាមសិប (៣០) ឆ្នាំមុន ហើយជនត្រូវចោទ អៀង សារី និង អៀង ធីរិទ្ធ មានពេលពិភាក្សាអំពីបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងការចោទប្រកាន់ "វាមានលក្ខណៈមិនច្បាស់លាស់សម្រាប់អង្គបុរេជំនុំជម្រះអំពីបញ្ហា

---

[៨] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទនឹងប្រពន្ធរបស់គាត់ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ A104/II/7 ("សេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមេសា")

[៩] សេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមេសា វាក្យខណ្ឌទី ១៨។

[១០] សេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមេសា វាក្យខណ្ឌទី ១៧។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC CETC

00225174

C33/I/7



ដែលថា ការកម្រិតទំនាក់ទំនងរវាងជនត្រូវចោទទាំងពីរនេះ ផ្តល់ការការពារដល់ផលប្រយោជន៍នៃកិច្ចស៊ើបសួរយ៉ាងដូម្តេច"។[១១]

១៤. សេចក្តីសម្រេចនេះធ្វើឡើង ដោយស្របនឹងដំហរ ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិ បានទទួលស្គាល់ នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Katanga និង Chui* ("សេចក្តីសម្រេចករណី *Chui*") ដោយនៅក្នុងរឿងក្តីនេះ ចៅក្រមនៃអង្គបុរេជំនុំជម្រះបានវិនិច្ឆ័យថា វិធានការ "កម្រិតទំនាក់ទំនងនិងការឆ្លើយឆ្លង" រវាងសហជនជាប់ចោទពីររូប "បង្កើតជាការកម្រិតចាំបាច់មួយលើសិទ្ធិដែលទទួលបាន តាមវិធានឃុំខ្លួន ដូចដែលមានចែងនៅក្នុងបទបញ្ជា និងបទបញ្ជារដ្ឋបាល។ ហេតុដូច្នេះហើយ វិធានការទាំងនេះអាចធ្វើទៅបាន ប្រសិនបើលក្ខខណ្ឌតម្រូវចាំបាច់ និងសមាមាត្រភាព បានបំពេញ។"[១២] នៅក្នុងសេចក្តីសម្រេចនេះ ដែលបង្ហាញចំនុចជាច្រើនដូចគ្នានឹងរឿងក្តី ដែលមាននៅចំពោះមុខអង្គបុរេជំនុំជម្រះ[១៣] ចៅក្រមបានបដិសេធចោលសំណើរបស់អយ្យការ ដែលស្នើសុំកម្រិតទំនាក់ទំនង និងការឆ្លើយឆ្លងរវាងសហជនជាប់ចោទពីររូប ដោយលើកឡើងថា អយ្យការមិនបានបង្ហាញ "ភស្តុតាងរឹងមាំ" ដែលបញ្ជាក់ថា សហជនជាប់ចោទ "អាចពិភាក្សាព័ត៌មានសំងាត់ ដើម្បីគម្រាមកំហែង ឬធ្វើបាបសាក្សី និង ជនរងគ្រោះ ឬដើម្បីបំពានដីកាមិនលាតត្រដាងភស្តុតាង ដែលចេញដោយចៅក្រម។"[១៤]

១៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញបន្ថែមទៀតថា គណៈកម្មាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស បានវិនិច្ឆ័យឃើញថា "ការផ្តាច់ទំនាក់ទំនងរបស់ទណ្ឌិតម្នាក់ចេញពីសង្គមគុកទូទៅ ទាំងស្រុង ឬ

---

[១១] សេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមេសា វាក្យខណ្ឌទី ១៩ និង វាក្យខណ្ឌទី២០។

[១២] ស្ថានភាពនៅក្នុងសាធារណៈរដ្ឋកុងហ្គោ នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kantanga និង Chui* ICC-01/04-01/07 សេចក្តីសម្រេចទាត់ចោលបម្រាមទំនាក់ទំនង រវាង Germain Katanga និង Mathieu Ngudjolo Chui" ចៅក្រមនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៨ ("សេចក្តីសម្រេចករណី *Chui*") ទំព័រទី ៩។

[១៣] ភាពស្រដៀងគ្នានឹងករណី នួន ជា ត្រូវបានបង្ហាញនៅក្នុងសេចក្តីសម្រេចនេះ៖ *រដ្ឋអាជ្ញា ទល់នឹង Katanga និង Chui* ICC-01/04-01/07 "ការសើរើសេចក្តីសម្រេចលើលក្ខខណ្ឌការឃុំខ្លួន Germain Katanga មុនអង្គសេចក្តី" ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ អង្គជំនុំជម្រះសាលាដំបូង។

[១៤] សេចក្តីសម្រេចករណី *Chui* ទំព័រទី ១០។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

ស្ទើរតែទាំងស្រុង ក្នុងរយៈពេលមួយយូរ គឺជាវិធានការមួយធ្ងន់ធ្ងរ។"[១៥] នៅក្នុងសេចក្ដីសម្រេចចំពោះសិទ្ធិទទួលការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប ឬសិទ្ធិទទួលបានការដោះលែងឱ្យមានសេរីភាព តុលាការអ៊ឺរ៉ុបផ្នែកសិទ្ធិមនុស្សបានរកឃើញថា ទោះបីហានិភ័យកើតមានជាទូទៅថា ចុងចោទអាចដាក់សម្ពាធលើសាក្សី ឬរំខានដល់កិច្ចដំណើរការនីតិវិធី ដោយសារមូលហេតុថា ចុងចោទជាសមាជិកមួយរូបនៅក្នុងក្រុម, "ប្រហែលអាច" ទទួលយកមកធ្វើជាមូលដ្ឋានសម្រាប់ការឃុំខ្លួននៅក្នុងដំណាក់ដំបូងក៏ដោយ, ដោយសារការកន្លងផុតនៃពេលវេលា យើងចាំបាច់ត្រូវមានកត្តាមួយទៀត ដែលអាចបង្ហាញថា ហានិយភ័យនេះពិតជាមានអត្ថិភាពមែន។[១៦]

១៦. តាមរយៈដីកាបង្គាប់ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ការកំណត់ "ការដាក់ឱ្យនៅដាច់ដោយឡែកមួយយ៉ាងតឹងរ៉ឹង" រវាងជនជាប់ឃុំ (លើកលែងតែករណីប្រពន្ធរបស់លោក អៀង សារី ហើយ អៀង ធីរិទ្ធ [...])"[១៧] ដែលជនជាប់ឃុំទាំងនេះ "គ្មានសិទ្ធិប្រាស្រ័យទាក់ទងគ្នា។"[១៨] ជាការពិតទៅ វាហាក់ដូចជាបង្ហាញឱ្យឃើញថា ជនត្រូវចោទ នួន ជា ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមវិធានការឱ្យនៅដាច់ដោយឡែកនេះ ចាប់តាំងពីពេលគាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧។

១៧. សហចៅក្រមស៊ើបអង្កេតបានដាក់វិធានការឱ្យនៅដាច់ដោយឡែកពីគ្នា ដោយផ្អែកលើមូលដ្ឋានដែលថា វាជាការត្រឹមត្រូវក្នុងការទប់ស្កាត់ "លទ្ធភាពខ្ពស់នៃការត្រូវរូវគ្នាដែលមានគ្រោះថ្នាក់" រវាងជនជាប់ចោទ។[១៩] តាមរយៈសម្អាងហេតុដែលបានលើកឡើងនៅក្នុងដីកាបង្គាប់ អង្គបុរេជំនុំជម្រះយល់ថា សហចៅក្រមស៊ើបអង្កេត បានយោងលើហានិភ័យថា ជនត្រូវចោទ

---

[១៥] *Reed ទល់នឹង ចក្រភពអង់គ្លេស* ពាក្យសុំលេខ ៧៦៣០/៧៦ ១៩ D.R ៩៥ at ១៣៦។

[១៦] *Gorski ទល់នឹង ប៉ូឡូញ* ពាក្យសុំលេខ ២៨៩០៤/០២ ថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៥ វាក្យខណ្ឌទី ៥៨ (គូសបញ្ជាក់បន្ថែម)

[១៧] ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន វាក្យខណ្ឌទី ៦។

[១៨] ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន ទំព័រទី ៥។

[១៩] ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន វាក្យខណ្ឌទី ៥។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

អាចឃុបឃិតគ្នា ដើម្បីដាក់សម្ពាធលើសាក្សី និង ជនរងគ្រោះ៖

> “វាបង្ហាញច្បាស់ថា(...) នៅពេលសហចៅក្រមស៊ើបអង្កេតចង្អុលបញ្ជាក់អំពីភាពចាំបាច់“*ក្នុងការរារាំងជនត្រូវចោទកុំឱ្យគាបសង្កត់សាក្សី ឬជនរងគ្រោះ*” វាបង្ហាញយ៉ាងច្បាស់ថា ជនត្រូវចោទមិនអាចទាក់ទងគ្នាឡើយ ដោយសារការត្រូវរូវគ្នា អាចជួយសម្រួលដល់ការគាបសង្កត់នេះ យ៉ាងពិតប្រាកដ ប្រសិនបើមានផលប៉ះពាល់ពីបណ្ដាញគាបសង្កត់នីមួយៗរបស់សហជនត្រូវចោទ។[២០]

១៨. សហចៅក្រមស៊ើបអង្កេតបានរកឃើញថា យោងតាមយុត្តិសាស្ត្ររបស់តុលាការអ៊ឺរ៉ុបផ្នែកសិទ្ធិមនុស្ស “ការឃុំខ្លួនមុនអង្គសេចក្ដីអាចត្រឹមត្រូវ ក្នុងចំណោមចំនុចទាំងឡាយ ដោយសារភាពចាំបាច់ដើម្បីរារាំងការត្រូវរូវគ្នារវាងសហជនជាប់ចោទ”។[២១] សហចៅក្រមស៊ើបអង្កេតបានបន្តទៀតថា “បើយោងតាមយុត្តិសាស្ត្ររបស់តុលាការអ៊ឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ដែលបានលើកឡើងនៅក្នុងកថាខណ្ឌខាងលើវិញ ការឃុំខ្លួនបណ្ដោះអាសន្ន និងលក្ខខណ្ឌនានាជាប់ពាក់ព័ន្ធនឹងការឃុំខ្លួន មិនអាចសម្អាងតែទៅលើភស្តុតាងនៃការប្រព្រឹត្តជាក់លាក់ប៉ុណ្ណោះទេ៖ ផ្ទុយទៅវិញ ចំនុចតែមួយគត់ដែលត្រូវយកមកពិចារណាគឺ ការវាយតម្លៃពីហានិភ័យ។”[២២]

១៩. សហមេធាវីការពារក្ដីសន្និដ្ឋានថា “សេចក្ដីសម្រេចរបស់ ក.ស.ច.ស. [ការិយាល័យសហចៅក្រមស៊ើបអង្កេត]” គួរតែបដិសេធ ដើម្បីបំពេញបំណងប្រាថ្នានៃសេចក្ដីសម្រេចរបស់ ICC ដែលតម្រូវ “ភស្តុតាងជុំកំភួន” នៃការត្រូវរូវគ្នា ដើម្បីធ្វើយុត្តិកម្មលើវិធានការតឹងរឹងដូចជាការដាក់ឃុំឱ្យនៅដាច់ដោយឡែកពីគ្នា។[២៣]សហមេធាវីការពារក្ដីអះអាងថា ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួនមិនបានចង្អុលបង្ហាញឱ្យបានច្បាស់ *ថាតើ* ការដាក់កំហិតមិនឱ្យទាក់ទងគ្នាទាំងស្រុងក្នុងចំណោមជនត្រូវចោទទាំងឡាយ ជាវិធានការចាំបាច់ដើម្បីការពារ [ផល

---

[២០] ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន វាក្យខណ្ឌទី ៤។

[២១] ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន វាក្យខណ្ឌទី ១ និង វាក្យខណ្ឌទី ២។

[២២] ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន វាក្យខណ្ឌទី ៣។

[២៣] បណ្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចលើលក្ខខណ្ឌឃុំខ្លួន ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៨ C33/I/3 (“សារណាបណ្ដឹងឧទ្ធរណ៍”) វាក្យខណ្ឌទី ២[illegible]



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

ប្រយោជន៍នោះយ៉ាងដូចម្ដេចដែរ]" ហើយសម្អាងហេតុនៅក្នុងសេចក្តីសម្រេច ចុះថ្ងៃទី៣០ ខែមេសា គួរត្រូវយកមកអនុវត្តនៅក្នុងរឿងក្តីនេះ។[២៤]

២០. ដូចគ្នានេះដែរ សហព្រះរាជអាជ្ញាយល់ឃើញថា ដោយសារ "ការបំបែកឱ្យនៅដាច់ដោយឡែកពីគ្នា គឺជាវិធានការដ៏តឹងរឹងបំផុតមួយ យុត្តិសាស្ត្ររបស់ ECHR និងសេចក្តីសម្រេចរបស់តុលាការ ICC នៅក្នុងរឿងក្តីរបស់ Katanga បង្ហាញឱ្យឃើញថា និន្នាការដើម្បីធ្វើយុត្តិកម្មចំពោះការបំបែកឱ្យនៅដាច់ដោយឡែកពីគ្នា មានលក្ខណៈខ្ពស់ជាងកម្រិតនៃការធ្វើយុត្តិកម្មចំពោះការឃុំខ្លួនបណ្តោះអាសន្នឆ្ងាយណាស់។ [...] ទោះបីជាអាចមានបញ្ហាស្តីពីគោលការណ៍នោះក្តី ក៏ការសម្រេចទាំងពីរនោះមានការលេចចេញនូវការពិចារណា និងអង្គហេតុដែលខុសគ្នា។"[២៥] សហព្រះរាជអាជ្ញាស្នើសុំអង្គបុរេជំនុំជម្រះឱ្យធ្វើសេចក្តីសម្រេចលើបណ្តឹងនេះ "ដោយផ្អែកតាមការសម្រេចពីមុន" នៅក្នុងសេចក្តីសម្រេចចុះ ថ្ងៃទី៣០ ខែមេសា។[២៦]

២១. ក្រោយពីពិចារណាយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស និងគណៈកម្មាការផ្នែកសិទ្ធិមនុស្ស អង្គបុរេជំនុំជម្រះពិចារណាឃើញថា សិទ្ធិទំនាក់ទំនង អាចត្រូវបានដាក់កម្រិត ដើម្បីការពារការដាក់សម្ពាធលើសាក្សី ឬជនរងគ្រោះ នៅពេលដែលមានភស្តុតាងសមរម្យ ដែលអាចបង្ហាញថា ពិតជាមានហានិភ័យដែលថា ជនត្រូវចោទអាចត្រូវរួវគ្នាជាមួយជនត្រូវចោទដទៃទៀត ដើម្បីដាក់សម្ពាធបែបនេះ ខណៈពេលខ្លួនកំពុងស្ថិតនៅក្រោមការឃុំខ្លួន។ ដោយសារការកន្លងផុតទៅនៃពេលវេលា និន្នាការមានការកើនឡើង នៅពេលដែលការស៊ើបអង្កេតកំពុងដំណើរការ និងហានិភ័យមានការថយចុះ។

២២. នៅពេលចេញដីកា សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញភស្តុតាងណាមួយដែលខ្លួនយកមកធ្វើជាមូលដ្ឋាន ហើយដែលភស្តុតាងនោះអាចបង្ហាញថាមានហានិភ័យជាក់ស្តែង ដែល

[២៤] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ១៦។

[២៥] សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា វាក្យខណ្ឌទី ២៨។

[២៦] សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា វាក្យខណ្ឌទី ៣០។

C33/I/7

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៩)

ថា ជនត្រូវចោទនឹងត្រូវរួវគ្នា ដើម្បីគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ខណៈពេលពួកខ្លួនកំពុងស្ថិតនៅក្រោមការឃុំខ្លួន។ អង្គហេតុដែលថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការចាំបាច់ ដើម្បីរារាំងជនត្រូវចោទពីការគាបសង្កត់លើលើសាក្សី និងជនរងគ្រោះ មិនមែនជាការនាំដល់ការសន្និដ្ឋានថា ជនត្រូវចោទអាចត្រូវរួវគ្នាដើម្បីគាបសង្កត់បែបនេះ ខណៈពេលពួកខ្លួនកំពុងស្ថិតនៅក្រោមការឃុំខ្លួន។ មូលដ្ឋាននៃការឃុំខ្លួន ដើម្បីរារាំងជនត្រូវចោទពីការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ គឺជាករណីដែលថា ប្រសិនបើមិនមានការឃុំខ្លួន បុគ្គលនេះអាចនឹងស្ថិតនៅកៀកនឹងសាក្សី និងជនរងគ្រោះ ឬបុគ្គលដែលខ្លួនអាចរៀបចំធ្វើការគាបសង្កត់បែបនេះដោយផ្ទាល់តែម្ដង។ ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត មិនមានភស្តុតាងគាំទ្រឡើយ។ ហេតុដូច្នេះហើយ ការសន្និដ្ឋាននេះ មិនគ្រប់គ្រាន់ក្នុងការផ្ដល់យុត្តិកម្មចំពោះការដាក់ជនជាប់ឃុំឱ្យនៅដាច់ដោយឡែកពីគ្នា។

២៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញទៀតថា នៅក្នុងរឿងក្ដីទាំងប្រាំនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែលសហចៅក្រមស៊ើបអង្កេតបានចេញដីកាបង្គាប់ការឃុំខ្លួនបណ្ដោះអាសន្ន គ្មានការលើកឡើងថា ការឃុំខ្លួនគឺជាវិធានការចាំបាច់ក្នុងការរារាំងការត្រូវរួវគ្នារវាងជនត្រូវចោទឡើយ។ ខណៈពេលខ្លួនកំពុងស្ថិតនៅក្រោមការឃុំខ្លួន ជនត្រូវចោទមិនមានទំនាក់ទំនងជាមួយសង្គមខាងក្រៅរួចទៅហើយ។ ជនត្រូវចោទមិនត្រឹមតែជាប់ឃុំប៉ុណ្ណោះទេ ខ្លួនថែមទាំងត្រូវបានដាក់ឱ្យស្ថិតនៅដាច់ដោយឡែកពីគ្នា តាមបង្គាប់របស់សហចៅក្រមស៊ើបអង្កេតអស់រយៈពេលប្រហែលជាមួយឆ្នាំ ដែលក្នុងអំឡុងពេលនេះ សហចៅក្រមស៊ើបអង្កេតមានឱកាសដើម្បីប្រមូលភស្តុតាងសំខាន់ៗ ដោយមិនមានការរំខានណាមួយដែលអាចកើតឡើងពីជនត្រូវចោទ។

២៤. នៅក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា វាអាចមិនមានហេតុផល ដែលពាក់ព័ន្ធនឹងគោលបំណងនៃការស៊ើបអង្កេត ដែលបញ្ជាក់ថា ការទំនាក់ទំនងរវាងជនត្រូវចោទទាំងប្រាំ ដែលនាពេលបច្ចុប្បន្ន ជាប់ឃុំនៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក គួរត្រូវដាក់កម្រិត។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

២៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញទៀតថា សហចៅក្រមស៊ើបអង្កេតបានលើកឡើងនៅក្នុងដីកាថា "ភាពចន្លោះនៃបទបញ្ញាច្បាស់លាស់នៃលក្ខខណ្ឌពិតប្រាកដនៃការឃុំខ្លួនជនត្រូវចោទ និងជាពិសេសការមិនទាន់ចូលជាធរមាននៃសេចក្តីព្រាង នៃបទបញ្ញាស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ [...] វា[ជា]ការចាំបាច់ដែលត្រូវបញ្ជាក់ពីមូលហេតុនៃការដាក់ឱ្យនៅដាច់ដោយឡែកពីគ្នារវាងជនដែលជាប់ឃុំ និងដែលចេញពីនេះកំណត់ពីលក្ខខណ្ឌនៃការឃុំខ្លួន[...]។"[២៧]

២៦. អង្គបុរេជំនុំជម្រះរំលឹកឃើញថា មន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងស្ថិតនៅក្រោមច្បាប់កម្ពុជា ដូចដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមេសា។[២៨] អនុលោមតាមច្បាប់កម្ពុជា ប្រធានមន្ទីរឃុំឃាំង ទទួលបន្ទុកការងាររដ្ឋបាលប្រចាំថ្ងៃ និងដំណើរការមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ដោយក្នុងនេះ រួមទាំងបញ្ហាសន្តិសុខផង។[២៩] ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន និងអនុលោមតាមវិធានទូទៅនៅក្នុងពន្ធនាគារទាំងអស់នៅក្នុងប្រទេសកម្ពុជា[៣០] ប្រធានមន្ទីរឃុំឃាំង នាពេលនេះ កំពុងអនុម័តវិធានទាំងឡាយ ដែលនឹងចែងជាក់លាក់លើលក្ខខណ្ឌនៃការឃុំឃាំងនៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ដោយក្នុងនោះរួមទាំងវិធានដែលពាក់ព័ន្ធនឹងសកម្មភាពប្រចាំថ្ងៃ[៣១] និងការឃ្លាំមើល[៣២] ជនជាប់ឃុំ។ វិធានទាំងនេះត្រូវតែទទួលការយល់ព្រមពីនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ។[៣៣] ករណីដែលថាវិធានទាំងនេះមិនទាន់បានអនុម័តជាផ្លូវការនៅឡើយ និងមិនទាន់ទទួលបានការយល់ព្រមពីនាយកដ្ឋានពន្ធនាគារ មិនបាន

---

[២៧] ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន ទំព័រទី ២។

[២៨] សេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមេសា វាក្យខណ្ឌទី ១០។

[២៩] ប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ ក្រសួងមហាផ្ទៃ លេខ ២១៧ ("ប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ") មាត្រា ១(១)(ក) មាត្រា ១(២)(ឆ) និង មាត្រា ៣(២)។ ប្រកាសនេះមានចែងនៅក្នុងសេចក្តីព្រាងស្តីពីការឃុំខ្លួនរបស់អ.វ.ត.ក។

[៣០] ប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ មាត្រា ៣(២)។

[៣១] វិធាន ២៧ នៃសេចក្តីព្រាងស្តីពីការឃុំខ្លួនរបស់អ.វ.ត.ក។

[៣២] វិធាន ២២ នៃសេចក្តីព្រាងស្តីពីការឃុំខ្លួនរបស់អ.វ.ត.ក។

[៣៣] ប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ មាត្រា ៣(២)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ដកហូតសិទ្ធិអំណាចរបស់ប្រធានមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ឡើយ អនុលោមតាមវិធាន ដែលកំពុងអនុវត្តចំពោះជនជាប់ឃុំនៅក្នុងប្រព័ន្ធពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជា នាពេលបច្ចុប្បន្ន។

២៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ជាធម្មតានៅក្នុងពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជា ជនជាប់ឃុំមិនត្រូវបានគេដាក់ឱ្យនៅដាច់ដោយឡែកពីគ្នាឡើយ[៣៤] ដូចដែលបានចែងនៅក្នុងសេចក្តីព្រាងនៃវិធានមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក។[៣៥] ការទំនាក់ទំនងរវាងជនជាប់ឃុំ ត្រូវបានកម្រិតដោយវិធានស្តីពីសកម្មភាពរាល់ថ្ងៃ និងការឃ្លាំមើលតែប៉ុណ្ណោះ។ នៅក្នុងកាលៈទេសៈមួយចំនួន ប្រធានមន្ទីរឃុំឃាំង មានអំណាចដាក់ជនជាប់ឃុំណាម្នាក់ឱ្យនៅដាច់ដោយឡែកពីជនជាប់ឃុំទាំងអស់ ឬមួយចំនួន ដើម្បីរក្សាសណ្តាប់ធ្នាប់នៅក្នុងមន្ទីរឃុំឃាំង និងរក្សាសន្តិសុខដល់ជនជាប់ឃុំ ដូចដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេច ចុះថ្ងៃទី៣០ ខែមេសា។

២៨. នៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមេសា អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន ៥៥ នៃវិធានផ្ទៃក្នុង ផ្តល់យុត្តាធិការដល់សហចៅក្រមស៊ើបអង្កេត ក្នុងការដាក់កម្រិតទំនាក់ទំនងរវាងជនជាប់ឃុំ ដើម្បីផលប្រយោជន៍នៃការស៊ើបអង្កេត។[៣៦] នៅពេលគ្មានការចែងផ្លូវច្បាប់ណាមួយ ដែលផ្តល់អំណាចនៃមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ដល់ខ្លួន សហចៅក្រមស៊ើបអង្កេតមិនមានអំណាចដាក់លក្ខខណ្ឌនៃការឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ឡើយ ដែលអំណាចនេះត្រូវស្ថិតនៅក្រោមអំណាចរបស់ប្រធានមន្ទីរឃុំឃាំង។

---

[៣៤] ចំនុចនេះអាចទាញចេញពីនីតិវិធីពន្ធនាគារ លេខ៣ -- ការបំបែកទណ្ឌិតឱ្យនៅដាច់ដោយឡែកពីគ្នា ដែលត្រូវបានអនុម័តស្របតាមមាត្រា ៤(៣) នៃប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ។

[៣៥] វិធាន ៣ នៃសេចក្តីព្រាងស្តីពីការឃុំខ្លួនរបស់អ.វ.ត.ក។

[៣៦] សេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមេសា វាក្យខណ្ឌទី ១៤។



អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

00225181

C33/I/7

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៩)

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច:**

១) ទទួលយកបណ្តឹងឧទ្ធរណ៍។

២) ច្រានចោលដីកាបង្គាប់លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨។

ភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨

**អង្គបុរេជំនុំជម្រះ**

Rowan DOWNING   ន័យ ថុល   Katinka LAHUIS   ហួត វុទ្ធី   ប្រាក់ គឹមសាន